# នួន ជា ដាក់លក្ខខណ្ឌក្នុងការផ្តល់សក្ខីកម្ម
# ចំណែក ឌុច ចាប់ផ្តើមធ្វើសក្ខីកម្ម

ដោយ វ៉េនឌល ឌីហ្សាល់កូ

ថ្ងៃទី១៩ ខែមិនា ឆ្នាំ២០១២

*ប្រែសម្រួលដោយ ដា ផល្លា*

នៅថ្ងៃច័ន្ទ ទី១៩ ខែមីនា ឆ្នាំ២០១២នេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានបន្តកិច្ចដំណើរការលើសំណុំរឿង០០២បន្តទៀត ។ កិច្ចដំណើរការថ្ងៃនេះត្រូវបានរំពឹងថា ជនជាប់ចោទ នួន ជា នឹងធ្វើសក្ខីកម្មបន្តទៀតទាក់ទងទៅនឹងប្រធានបទអំពីរចនាសម្ព័ន្ធរដ្ឋបាល និងទំនាក់ទំនងនៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងតួនាទីរបស់ជនជាប់ចោទចំពោះរចនាសម្ព័ន្ធទាំងពីរនេះ ដូចដែលបានរៀបរាប់នៅក្នុងកថាខណ្ឌមួយចំនួននៃដីកាដំណោះស្រាយរួចហើយ ។

មុននឹងចាប់ផ្តើមធ្វើសក្ខីកម្ម អង្គជំនុំជម្រះប្រកាសថា នឹងមានការផ្លាស់ប្តូរកម្មវិធីតិចតួចដោយរចនាសម្ព័ន្ធរដ្ឋបាលនឹងយកមកពិភាក្សាមុន ហើយក្រោយមកនឹងពិភាក្សាអំពីតួនាទីនិងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងបីនាក់ ។ ក្រោយមក អង្គជំនុំជម្រះផាកទៅពិភាក្សាប្រធានបទអំពីរចនាសម្ព័ន្ធទំនាក់ទំនង ។

ខណៈពេលដែល នួន ជា កំពុងត្រូវបាននាំខ្លួនចូលមកកាន់ទីក្រចកសេះ មេធាវីរបស់គាត់ម៉ៃខល ផេសមិន បានស្នើថា នួន ជា គួរតែទទួលបានឱកាសដើម្បីអានសេចក្តីថ្លែងការណ៍ដ៏ខ្លី ដែលបានដាក់ជូនតុលាការរួចហើយ ដើម្បីឆ្លើយទៅនឹងសំណួរដែលចោទសួរដោយព្រះរាជអាជ្ញា ។ ចៅក្រមអង្គជំនុំជម្រះបានប្រាប់ទៅក្រុមការពារក្តីរបស់ នួន ជា មួយចំនួនមុននឹងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ឡើងអានសេចក្តីថ្លែងការណ៍ ។

## សេចក្តីថ្លែងការណ៍របស់ នួន ជា

នួន ជា បានអានសេចក្តីថ្លែងការណ៍របស់គាត់ដោយបញ្ជាក់ថា ទោះបីជាកិច្ចដំណើរការនេះគឺដើម្បីស្វែងរកការពិតក៏ដោយ អង្គជំនុំជម្រះនេះមិនបានពិនិត្យមើលវិសាលភាពឲ្យបានទូលំទូលាយនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រដើម្បីថតរូបភាពដ៏ធំធេងនៃអតីតកាលទេ ។ ក្រោយមក នួន ជា បាននិយាយថា អង្គជំនុំជម្រះស្វែងយល់តែ«ក្បាលក្រពើ»ប៉ុណ្ណោះ តែមិនបានស្វែងយល់ពីរូបរាងទាំងមូល

របស់ក្រពើនោះទេ។ នួន ជា បានសួរថា តើអង្គជំនុំជម្រះស្វែងយល់ពីសកម្មភាពរបស់គាត់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដោយមិនបានពិចារណាអំពីហេតុការណ៍មុននឹងមានរបបកម្ពុជាប្រជាធិបតេយ្យម្ដេចបាន ព្រោះមុននឹងមានរបបកម្ពុជាប្រជាធិបតេយ្យ ប្រទេសជាតិត្រូវបានញាំញីដោយភាពវឹកវរ អំពើពុករលួយ ទុរ្ភិក្ស អំពើហិង្សា និងអំពើកាប់សម្លាប់ ព្រមទាំងអំពើអបាយមុខ ជាច្រើនទៀត។ នួន ជា ក៏បានបញ្ជាក់ទៀតថា ការទម្លាក់គ្រាប់បែកបេ-៥២របស់សហរដ្ឋអាមេរិកនៅកម្ពុជាក៏ត្រូវតែយកមកពិភាក្សាដែរ ព្រោះការទម្លាក់គ្រាប់នោះបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធ និងលទ្ធភាពនៃការបង្កបង្កើនផលអស់ជាច្រើន។ នួន ជា បានបន្ថែមទៀតថា ព្រឹត្តិការណ៍ទាំងនេះរួមទាំងសង្គ្រាមស៊ីវិលពីឆ្នាំ១៩៧០ដល់១៩៧៥មុននឹងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យប្រទេសកម្ពុជា«ខ្ទេចខ្ទីអស់ទៅហើយ» នៅពេលដែលខ្មែរក្រហមឡើងកាន់អំណាច។ ក្រោយមក នួន ជា បានត្រលប់ទៅរិះគន់ប្រទេសវៀតណាមដែលគាត់បានអះអាងថា វៀតណាមក៏មានការទទួលខុសត្រូវខ្លះដែរ ក្នុងការបង្ករឲ្យមានភាពវឹកវរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

នួន ជា បានព្យាយាមបង្វែរការបន្ទោសមកលើខ្មែរក្រហម ដោយបន្ទោសការបំផ្លិចបំផ្លាញរចនាសម្ព័ន្ធប្រទេស ការរាលដាលជំងឺនិងការអត់ឃ្លាន និងបញ្ហាផ្សេងទៀតទៅលើកត្តាផ្សេងទៀតជាពិសេសសហរដ្ឋអាមេរិក និងវៀតណាម។ ក្រោយមក នួន ជា បានស្នើទៅអង្គជំនុំជម្រះឲ្យបន្ថែមសាក្សីមួយចំនួនទៀតដែលស្នើដោយក្រុមរបស់ នួន ជា ដោយបញ្ជាក់ពីមូលហេតុថា មានតែក្រុមសាក្សីទាំងនេះទេ ដូចជាមន្ត្រីយោធាអាមេរិកជាដើម ទើបអាចប្រាប់អង្គជំនុំជម្រះអំពីការបំផ្លិចបំផ្លាញដែលបង្កឡើងដោយការទម្លាក់គ្រាប់បែករបស់អាមេរិកនេះ។

នួន ជា បានស្នើទៅអង្គជំនុំជម្រះឲ្យពិចារណាពិនិត្យមើលប្រាំចំណុចដូចជា ៖

- ការទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិកពីឆ្នាំ១៩៦៥ដល់ឆ្នាំ១៩៧៣ ដែលបង្កឲ្យមានការស្លាប់ និងការបំផ្លាញហេដ្ឋារចនាសម្ព័ន្ធប្រទេសអស់ជាច្រើន
- ស្ថានភាពម្ហូបអាហារនៅក្នុងប្រទេសកម្ពុជាមុនឆ្នាំ១៩៧៥ និងបញ្ហាទាក់ទងនឹងការអត់ឃ្លាន និងបញ្ហាជនភៀសខ្លួន
- ចំនួនស្រូវដែលមានសម្រាប់ហូបនៅទីក្រុងភ្នំពេញមុនឆ្នាំ១៩៧៥
- បញ្ហាថែទាំសុខភាពក្នុងអំឡុងសង្គ្រាមស៊ីវិល (១៩៧០-១៩៧៥) និងបញ្ហាទាក់ទងទៅនឹងជំនួយមនុស្សធម៌របស់អាមេរិកក្នុងអំឡុងពេលនោះ និង
- ទំនាក់ទំនងរវាងវៀតណាមនិងបក្សកុម្មុយនីស្តកម្ពុជា។

ក្រោយមក នួន ជា បានបន្ទោសការិយាល័យសហចៅក្រមស៊ើបអង្កេតថាបានធ្វើការស្រាវជ្រាវភ័ស្តុតាងតែក្នុងករណី០០២ប៉ុណ្ណោះ ។ នួន ជា បានតវ៉ាថា ដីកាដំណោះស្រាយដែលចេញដោយការិយាល័យសហចៅក្រមស៊ើបអង្កេតគឺឆ្លុះបញ្ចាំងតែការដាក់សំណើជាបឋមនៃការដាក់ទោសតែប៉ុណ្ណោះ និងមិនបានក្រឡេកមើលឲ្យបានគ្រប់គ្រាន់នៅក្នុងបញ្ហានេះទេ ហើយភាគីការពារក្តីត្រូវបានហាមឃាត់ដោយច្បាប់របស់អង្គជំនុំជម្រះក្នុងការស៊ើបអង្កេតដោយខ្លួនឯង ។

## ព្រះរាជអាជ្ញាជំទាស់ទៅនឹងវិសាលភាពនៃសេចក្តីថ្លែងការណ៍របស់ នួន ជា

ត្រង់ចំណុចនេះ មេធាវីរបស់ព្រះរាជអាជ្ញា ឌេល លីសាក់ បានជំទាស់ដោយបញ្ជាក់ថា អ្វីដែល នួន ជា និយាយទាំងអម្បាលមាណនេះ មិនពាក់ព័ន្ធទៅនឹងប្រធានបទដែលកំពុងតែពិភាក្សនៅពេលនេះទេ ។ លីសាក់ បានចោទ នួន ជា ថាបានអះអាងប្រាំដែលនូវអ្វីដែលមេធាវីការពារក្តីរបស់ខ្លួនបានបញ្ជាក់រួចហើយកាលពីសវនាការមុនៗ ។ លីសាក់ បានបន្ថែមទៀតថា ក្រុមការពារក្តីមិនបានលើកពីបញ្ហានេះឲ្យបានគ្រប់គ្រាន់ទេ តាមរយៈការដាក់បញ្ចូលឯកសារអំឡុងពេលនៃសវនាការដែលនិយាយ អំពីហេតុការណ៍មុនរបបកម្ពុជាប្រជាធិបតេយ្យ ហើយដូច្នេះ មេធាវីការពារក្តីមិនគួរអះអាងថា អង្គជំនុំជម្រះមិនបានផ្តល់ឱកាសដល់ខ្លួនដើម្បីនិយាយទេ ។ ទីបញ្ចប់ លីសាក់ បានអះអាងថា អ្វីដែល នួន ជា បាននិយាយ គឺ“មិនមានលក្ខណៈសមហេតុផលទេ” ហើយពេលដែលគាត់និយាយអង្គជំនុំជម្រះគួរតែបញ្ឈប់គាត់ ពេលណាដែលគាត់និយាយមិនត្រូវនឹងប្រធានបទ ។

មេធាវី ម៉ៃខល ផេសមិន បានឆ្លើយការពារកូនក្តីដោយបញ្ជាក់ថា អ្វីដែល នួន ជា និយាយគឺទាក់ទងទៅនឹងផ្នែកថ្មីៗនៃដំណាក់កាលករណី០០២នេះ ហើយបន្ថែមទៀតថា នួន ជា ហៀបនឹងបញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ហើយមុននឹងកូនក្តីរបស់គាត់ត្រូវបានប្រាប់ឲ្យបញ្ចប់ ។

អង្គជំនុំជម្រះបានឯកភាពទៅនឹងការជំទាស់របស់ព្រះរាជអាជ្ញា និងណែនាំទៅ នួន ជា ឲ្យផ្អាកសេចក្តីថ្លែងការណ៍របស់គាត់ដោយបញ្ជាក់ថា គាត់បាននិយាយច្រើន ហើយប្រធានបទនោះមិនទាក់ទងទៅនឹងប្រធានបទដែលកំពុងតែពិភាក្សានៅពេលនេះទេ ។ អង្គជំនុំជម្រះបានប្រគល់តួនាទីនេះទៅចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ឲ្យចោទសួរទៅ នួន ជា ។ មេធាវី ផេសមិន ឡើងនិយាយភ្លាមដោយស្នើសុំអង្គជំនុំជម្រះចំនួនប្រាំនាទីដើម្បីពិភាក្សាជាមួយកូនក្តីរបស់ខ្លួនសិន ។ សំណើនេះត្រូវបានបដិសេធដោយចៅក្រម និល ណុន ដែលអះអាងថា មេធាវីនិងជនជាប់ចោទមានពេលគ្រប់គ្រាន់ក្នុងការពិភាក្សារួចហើយមុននិងមកចូលក្នុងទីនេះ ។

## ចៅក្រម ខាត់រ៉ាយថ៍ ព្យាយាមតែបរាជ័យក្នុងការសួរសំណួរទៅ នួន ជា

ក្រោយមក ចៅក្រម ខាត់រ៉ាយថ៍ បានព្យាយាមសួរទៅកាន់ នួន ជា ដោយងាកប្រធានបទទៅសួរអំពីមនោគមន៍វិជ្ជា និងមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាដែលបានពិភាក្សាក្នុងអំឡុងពេលដំណើរការសវនាការដំបូងថ្ងៃនេះ ហើយមនោគមន៍និងមាគ៌ានយោបាយទាំងអស់នេះក៏មាននៅក្នុងលក្ខន្តិករបស់បក្សកុម្មុយនីស្តកម្ពុជាដែរ ។ លោកស្រីចៅក្រមក៏បានបញ្ជាក់ដែរថា អង្គជំនុំជម្រះមានបំណងចង់ដឹងអំពីលក្ខន្តិកបក្សមកត្រឹមឆ្នាំ១៩៧៥ ដោយបញ្ជាក់ថា នួន ជា គឺ«ជាបុគ្គលដ៏ត្រឹមត្រូវបំផុត» ដើម្បីជួយដល់តុលាការឲ្យដឹងពីលក្ខន្តិកបក្សនេះ ។

នួន ជា បានឆ្លើយថា គាត់នឹងរក្សាសិទ្ធិនៅស្ងៀមដោយមិនឆ្លើយតបអ្វីទាំងអស់លុះត្រាតែគាត់ត្រូវបានផ្តល់ឱកាសឲ្យនិយាយជាមួយមេធាវីរបស់គាត់សិន ។

ចៅក្រម ខាត់រ៉ាយថ៍ បានសួរទៅ នួន ជា ថាតើគាត់ចង់ពិគ្រោះជាមួយមេធាវីរបស់ខ្លួនដែរឬទេ? ចំណុចនេះធ្វើឲ្យមេធាវី ផេសមិន ឡើងសួរភ្លាមដោយអះអាងថា សំណួរនេះមិនមានលក្ខណៈសមរម្យទេ ។ អ្វីដែលមេធាវី ផេសមិន អះអាងត្រូវបានជំទាស់ដោយចៅក្រមកាលពីដំបូង ។ តែដោយសារតែមេធាវី ផេសមិន នៅតែជម្នះសួរតទៅទោះបីជាគាត់មិនត្រូវបានប្រាប់ឲ្យសួរក៏ដោយ ។ មេធាវី ផេសមិន បានបញ្ជាក់ថា វាជារឿងមិនត្រឹមត្រូវទេដែលចៅក្រមសួរសំណួរបែបនេះទៅកាន់ជនជាប់ចោទទាក់ទងទៅនឹងប្រធានបទដែលជនជាប់ចោទនិងពិភាក្សាជាមួយមេធាវីនោះ ហើយមេធាវី ផេសមិន បានណែនាំទៅ នួន ជា ថាមិនបាច់ត្រូវឆ្លើយសំណួរនេះទេ ។

ការជជែកតវ៉ាគ្នានេះត្រូវបានជាប់គាំង ហើយចៅក្រមអង្គជំនុំជម្រះបានជំនុំគ្នាមួយសន្ទុះដើម្បីពិភាក្សាពីបញ្ហានេះ ។នៅពេលដែលចៅក្រមចាប់ផ្តើមពិភាក្សាគ្នា ម៉ៃក្រូហ្វូនរបស់ចៅក្រម ខាត់រ៉ាយថ៍ បានបើក ហើយគ្រានោះ លោកស្រីចៅក្រមបាននិយាយ “ខ្ញុំគិតថា ជនជាប់ចោទគួរតែត្រូវបានអនុញ្ញាតឲ្យពិគ្រោះជាមួយមេធាវីរបស់ខ្លួនពីមុនរួចហើយ» ទៅកាន់ចៅក្រមផ្សេងទៀត ។ ការពិភាក្សាគ្នានេះទំនងជានិយាយអំពីសំណើរបស់ក្រុមការពារក្តីរបស់ នួន ជា ទាក់ទងទៅនឹងថាតើគួរឲ្យ នួន ជា ឡើងនិយាយឬយ៉ាងណា? ក្រោយពីពិភាក្សាគ្នារួច អង្គជំនុំជម្រះបានយល់ព្រមទៅនឹងសំណើរបស់ នួន ជា ហើយ នួន ជា ត្រូវបានផ្តល់សិទ្ធិឲ្យនិយាយជាមួយមេធាវីរបស់គាត់ ។

## នួន ជា ទាមទារចង់និយាយបញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់

ក្រោយពីពិភាក្សារួច មេធាវី ផេសមិន បានជូនដំណឹងទៅអង្គជំនុំជម្រះថា នួន ជា បានស្នើសុំអានបន្តដើម្បីបញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ ។ មេធាវីរូបនេះក៏បានជូនដំណឹងទៅអង្គជំនុំជម្រះ

ថា ប្រសិនជាអង្គជំនុំជម្រះមិនអនុញ្ញាតទេ នួន ជា នឹងសុំសិទ្ធិនៅស្ងៀមដោយមិននិយាយអ្វីនឹងមិនឆ្លើយសំណួរអ្វីទាំងអស់សម្រាប់ថ្ងៃនេះ ។

ក្រោយពីមេធាវីនិយាយចប់ ចៅក្រមបានពិគ្រោះគ្នាម្តងទៀត អស់រយៈពេលជាច្រើននាទី ហើយក្រោយមក ចៅក្រម និល ណុន បានប្រកាសថា នួន ជា ត្រូវបានផ្តល់សិទ្ធិឲ្យបញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ តែអង្គជំនុំជម្រះបានរំឭកទៅ នួន ជា ឲ្យនិយាយឲ្យខ្លីនិងត្រូវចំណុចក្នុងដំណាក់កាលទីពីរនៃករណី០០២ វគ្គពីរនេះ ។ ចៅក្រម និល ណុន បានបញ្ជាក់ថា អង្គជំនុំជម្រះចង់កត់សម្គាល់ពី«អកប្បកិរិយា»មេធាវីការពារក្តីរបស់ នួន ជា អំឡុងពេលនៃដំណើរការនេះ ។

## នួន ជា បញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់

ក្រោយមក នួន ជា បានចាប់ផ្តើមអានសេចក្តីថ្លែងការណ៍របស់គាត់ដោយត្រលប់ទៅនិយាយពីការអង្កេតរបស់គាត់ទាក់ទងទៅនឹងការិយាល័យសហចៅក្រមស៊ើបអង្កេត និងអ្វីដែលក្រុមការពារក្តីមិនមានឱកាសធ្វើការស៊ើបអង្កេតដោយខ្លួនឯង ។ នួន ជា បានបញ្ជាក់ថា ការដែលការិយាល័យសហចៅក្រមស៊ើបអង្កេតបដិសេធនូវសំណើក្នុងការស៊ើបអង្កេតរបស់ក្រុមការពារក្តី គាត់ហាក់បីដូចជា ចូលមកក្នុងតុលាការនេះដោយ«ដៃទទេ»ដូច្នោះដែរ ។ នួន ជា បានស្នើថា ចៅក្រម«មានសិទ្ធិពេលពេញក្នុងការស្វែងរកការពិត» ។ ក្រោយមក នួន ជា បានស្នើទៅចៅក្រមពិនិត្យលើបញ្ហាខាងក្រោមនេះឲ្យខានតែបាន ៖

១. បន្តស្រាវជ្រាវប្រវត្តិសាស្ត្រមុនឆ្នាំ១៩៧៥

២. ស្តាប់សក្ខីកម្មសាក្សីបន្ថែមដែលក្រុមរបស់គាត់បានស្នើ និង

៣. អនុញ្ញាតឲ្យក្រុមការពារក្តីរបស់គាត់ អាចដាក់ឯកសារនៅចំពោះមុខតុលាការ រហូតដល់ពេលបញ្ចប់នៃដំណើរការកាត់ទោសទាំងមូល ។

ក្រោយមក នួន ជា បានសួរទៅអង្គជំនុំជម្រះថាតើបានសម្រេចយ៉ាងម៉េចហើយទាក់ទងទៅនឹងសំណើរបស់គាត់កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២នោះ ហើយគាត់បានជូនដំណឹងទៅអង្គជំនុំជម្រះថា បើសិនជាក្រុមការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យលើកពីប្រធានបទមុនរបបកម្ពុជាប្រជាធិបតេយ្យមកនិយាយទេ គាត់នឹងរក្សាសិទ្ធនៅស្ងៀមចាប់ពីពេលនេះតទៅ ។

## ដើមបណ្តឹងរដ្ឋប្បវេណីសម្តែងការមិនយល់ព្រមចំពោះជំហររបស់ នួន ជា

ក្រោយពី នួន ជា និយាយចប់ សហមេធាវីនាំមុខអន្តរជាតិ អេលីហ្សាបេត ស៊ីម៉ូណូហ្វូត បានក្រោកឈរនិងរៀបរាប់ពី«ភាពក្រេវក្រោត» ដែលភាគីដើមបណ្តឹងរដ្ឋប្បវេណីមានទាក់ទងទៅនឹងជំហររបស់ក្រុមការពារក្តី ហើយបានហៅទម្រង់នេះថាជា«ការស៊ីសំណូក»។ អេលីហ្សាបេត បានបញ្ជាក់ថា អង្គជំនុំជម្រះមិនមែនបង្កើតឡើងសម្រាប់តែ នួន ជា តែម្នាក់នោះទេ តែបង្កើតឡើងសម្រាប់គ្រប់ភាគីទាំងអស់គ្នា រួមទាំងដើមបណ្តឹងរដ្ឋប្បវេណីផង ហើយលោកស្រីបានស្នើទៅអង្គជំនុំជម្រះឲ្យជូនដំណឹងទៅ នួន ជា ថា គាត់មិនត្រូវបានអនុញ្ញាតឲ្យប្រើពាក្យផ្តាច់ការក្នុងអំឡុងពេលសវនាការនេះទេ។

## ព្រះរាជអាជ្ញារំឮកទៅតុលាការអំពីវិសាលភាពនៃការសួរសំណួរសម្រាប់សាក្សី ដែលមិនមែនជាភាគីណាមួយ

ក្រោយមក ព្រះរាជអាជ្ញាក៏បានឆ្លើយតបវិញដែរ ដោយផ្តល់ការគាំទ្រជំហររបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ឌុល លីសាក់ បានបញ្ជាក់ថា មានតែសក្ខីកម្មរបស់ជនជាប់ចោទក្នុងអំឡុងពេលសវនាការប៉ុណ្ណោះ ដែលនឹងត្រូវបែងចែកជាច្រើនបំណែក ហើយសាក្សីដែលនឹងមកធ្វើសក្ខីកម្មនៅថ្ងៃអនាគតគួរតែចោទសួរគ្រប់ប្រធានបទទាំងអស់ រួមទាំងសំណួរពីដំណាក់កាលដំបូងរបស់របបកម្ពុជាប្រជាធិបតេយ្យផង។ ឌុល លីសាក់ បានបញ្ជាក់ថា ព្រះរាជអាជ្ញានឹងរង់ចាំអង្គជំនុំជម្រះចេញសេចក្តីបង្គាប់ទាក់ទងនឹងបញ្ហានេះ។

ក្រោយមក អង្គជំនំជម្រះប្រកាសថា អង្គជំនុំជម្រះទុកពេលជិតមួយម៉ោងដើម្បីពិចារណាអំពីការអភិវឌ្ឍន៍ថ្មីៗទាក់ទងទៅនឹងសក្ខីកម្មរបស់ នួន ជា ។

## អៀង សារី ហត់នឿយនិងស្នើទៅកាន់បន្ទប់រង់ចាំដូចសព្វដង

មកដល់ចំណុចនេះ លោក អាង ឧត្តម មេធាវីការពារក្តីរបស់ អៀង សារី បានក្រោកឈរនិងស្នើដូចរាល់លើកថា អៀង សារី សុំលះបង់សិទ្ធមានវត្តមាននៅក្នុងតុលាការ ហើយចង់ទៅសម្រាកនៅក្នុងបន្ទប់រង់ចាំវិញ។ ចៅក្រមអនុញ្ញាត និងជូនដំណឹងទៅជនជាប់ចោទឲ្យប្រគល់លិខិតជាលាយលក្ខណ៍អក្សរដែលមានហត្ថលេខា ឬស្នាមម្រាមដៃរបស់ជនជាប់ចោទដាក់មកកាន់អង្គជំនុំជម្រះ។

## អង្គជំនុំជម្រះបដិសេធសំណើរបស់ នួន ជា

ក្រោយពីសម្រាក អង្គជំនុំជម្រះបានប្រកាសថា អង្គជំនុំជម្រះបាន«ពិនិត្យ»មើលសំណើរបស់ នួន ជា រួចហើយដែលបានដាក់ជូនកាលពីព្រឹកមិញ។ ចៅក្រម និល ណុន បានបញ្ជាក់ថា សំណើ

នោះគឺ“ជាសំណើចាស់” ដែលធ្លាប់លើកមកនិយាយរួចហើយ ។ ចៅក្រមបានបញ្ជាក់ថា សំណើខ្លះត្រូវបានសម្រេចរួចហើយ ហើយសេចក្ដីសម្រេចផ្សេងទៀតកំពុងតែពិចារណា ។ ប្រធានចៅក្រមបានសួរ នួន ជា ថា តើគាត់ត្រៀមខ្លួនរួចរាល់ហើយឬនៅដើម្បីឆ្លើយសំណួរទាក់ទងទៅនឹងប្រធានបទថ្មីៗ?

## នួន ជា បដិសេធមិនព្រមធ្វើសក្ខីកម្ម

នួន ជា បានឆ្លើយបតដោយថ្លែងអំណរគុណដល់អង្គជំនុំជម្រះដែលបានផ្ដល់ឱកាសដល់គាត់ឲ្យពិគ្រោះជាមួយមេធាវីរបស់ខ្លួន ហើយមានឱកាសបញ្ចប់សេចក្ដីថ្លែងការណ៍របស់គាត់ ។ នួន ជា បានបញ្ជាក់ថា នៅពេលនេះ អង្គជំនុំជម្រះកំពុងតែដំណើរការប្រធានបទផ្សេង ហើយគាត់សុំសិទ្ធិនៅស្ងៀមមួយរយៈ ។ គាត់បានបញ្ជាក់ទៀតថា ការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបាន“ធ្វើឡើងដោយចាំបាច់បំផុត” និងសមស្របតាមបទដ្ឋានអន្តរជាតិ ។

## អង្គជំនុំជម្រះសម្រេចឲ្យ ឌុច ចូលមកធ្វើសក្ខីកម្ម

អង្គជំនុំជម្រះបានប្រកាសថា កាលវិភាគសម្រាប់ថ្ងៃនេះ មានការផ្លាស់ប្ដូរខ្លះ ដោយអង្គជំនុំជម្រះសម្រេចឲ្យ កាំង ហ្គេចអ៊ាវ ហៅ ឌុច ចូលមកធ្វើសកម្មចាប់ពីម៉ោងពីររសៀលនេះ មិនមែនថ្ងៃស្អែកទេ ។

មកដល់ចំណុចនេះ ឌេល លីសាក់ បានរំឭកទៅអង្គជំនុំជម្រះថា ភាគីព្រះរាជអាជ្ញាបានធ្វើសំណើរួចហើយទាក់ទងទៅនឹងដំណើរការនៃការធ្វើសេចក្ដីថ្លែងការណ៍របស់ជនជាប់ចោទ ខៀវ សំផន ទៅកាន់អង្គជំនុំជម្រះ ហើយ ខៀវ សំផន ជំទាស់មិនធ្វើសក្ខីកម្មទេ ។ ឌេល លីសាក់ បានជូនដំណឹងទៅ អង្គជំនុំជម្រះថា នៅពេលនេះ នួន ជា ក៏មិនធ្វើសក្ខីកម្មដែរ ហើយដោយសារតែហេតុផលដូច្នេះនេះ

ជាភារកិច្ចរបស់អង្គជំនុំជម្រះក្នុងការសម្រេចថាតើជាការចាំបាច់ដែរឬទេក្នុងការស្ដាប់សក្ខីកម្មរបស់ នួន ជា នូវសេចក្ដីថ្លែងការណ៍ដែលជនជាប់ចោទរូបនេះបានដាក់ជូនអង្គសវនាការហើយនោះ ។

ចៅក្រម និល ណុន បានថ្លែងអំណរគុណដល់ព្រះរាជអាជ្ញាចំពោះការអង្កេតនេះ ហើយចៅក្រមបានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ឲ្យសម្រាករហូតដល់ម៉ោងពីររសៀល ។

## ព័ត៌មានទាក់ទងទៅនឹងបញ្ហាមិនទាន់ដោះស្រាយរួចកាលពីព្រឹកមិញ

ក្រោយពីសម្រាកអស់រយៈពេលយ៉ាងយូរមក  អង្គជំនុំជម្រះបានចាប់ផ្តើមដំណើរការឡើងវិញ ដោយដំបូងបានធ្វើការសង្កេតទៅលើបញ្ហាដែលបានកើតឡើងកាលពីព្រឹកមិញ ។ ប្រធានចៅក្រម និល ណុន បានផ្តល់តួនាទីនេះទៅចៅក្រម ហ្សង់មាក ឡាវែន់  ដោយបានរំឭកដល់គ្រប់ភាគីនិងមេធាវីទាំងអស់ថា ប្រធានបទសម្រាប់ថ្ងៃនេះត្រូវបានជូនដំណឹងទៅគ្រប់ភាគីទាំងអស់រួចហើយ ។ ចៅក្រម ឡាវែន់ បានបញ្ជាក់ទៀតថា  អង្គជំនុំជម្រះមានគម្រោងនឹងត្រួតពិនិត្យមើលផ្នែកខ្លះនៃដីកាដំណោះស្រាយដែលរៀបរាប់ពីប្រធានបទសម្រាប់ពេលនេះ ។ ក្រោយមកចៅក្រម និល ណុន បានស្នើទៅលោក ម៉ៃខល ផេសមិន មេធាវីរបស់ នួន ជា ឲ្យបញ្ជាក់ឲ្យច្បាស់ថាតើអ្វីដែលរៀបរាប់នៅក្នុងសំណើដែលបានដាក់ជូនមកអង្គជំនុំជម្រះនោះមានការពាក់ព័ន្ធនឹងប្រធានបទសម្រាប់ថ្ងៃនេះដែរឬអត់? ចៅក្រម ឡាវែន់ បានបន្ថែមលើនោះទៀតថា ទោះបីជាមានការធានាចំពោះអង្គជំនុំជម្រះថា អ្វីដែល នួន ជា ដាក់ជូននោះមិនស៊ីគ្នានឹងប្រធានបទសម្រាប់ថ្ងៃនេះក៏ដោយ ក៏មេធាវី ផេសមិន បាន«លើកទឹកចិត្ត»ឲ្យ នួន ជា ធ្វើសេចក្តីថ្លែងការណ៍ខុសដែនកំណត់របស់ប្រធានបទសម្រាប់ថ្ងៃនេះដែរ ។ ចៅក្រម និល ណុន បានបន្តទៀតថា អង្គជំនុំជម្រះអនុញ្ញាតឲ្យ នួន ជា បញ្ចប់សេចក្តីថ្លែងការណ៍របស់គាត់ ដើម្បីឆ្លើយតបទៅនឹងព្រះរាជអាជ្ញា តែអ្វីដែល នួន ជា និយាយនៅតែមិនត្រូវប្រធានបទសម្រាប់ថ្ងៃនេះទេ ។ ចៅក្រម ឡាវែន់ បានពន្យល់ថា អង្គជំនុំជម្រះមានយោបល់ថា មេធាវី ផេសមិន មានបំណងបង្វែអង្គជំនុំជម្រះឲ្យផ្លាស់ប្តូរដំណាក់កាលនៃដំណើរការនេះ ។ លោកចៅក្រមបានបញ្ជាក់ថា «អ្វីដែលមេធាវី ផេសមិន ធ្វើនេះ បង្កឲ្យមានចោទជាសំណួរទាក់ទងទៅនឹងក្រមសីលធម៌» ហើយចៅក្រមបានជូនដំណឹងទៅគ្រប់ភាគីទាំងអស់ថា  អង្គជំនុំជម្រះអាចនឹងពិចារណាថា  នឹងចាត់វិធានការណ៍បែបណាចំពោះបញ្ហានេះ ។ ក្រោយពីនិយាយចប់ អង្គជំនុំជម្រះបានបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនសាក្សី ឌុច មកកាន់កន្លែងសាក្សីអង្គុយ ។

## ព្រះរាជអាជ្ញាចោទសួរទៅ ឌុច

ឌុច  ដែលជាពិរុទ្ធជនក្នុងករណី០០១  បានធ្វើការស្បថស្បែ  ហើយចាប់ផ្តើមធ្វើសក្ខីកម្ម ។ មេធាវីរបស់ព្រះរាជអាជ្ញា សេង ប៊ុនយាង បានបង្ហាញពីគម្រោងត្រួសៗនៃសំណួរដែលត្រូវសួរមុននឹងរំឭកទៅ ឌុច អំពីវត្តមានរបស់គាត់ជាសាក្សី មិនមែនជាជនជាប់ចោទទេ ។ ព្រះរាជអាជ្ញាចាប់ផ្តើមសួរសំណួរទៅកាន់ ឌុច អំពីប្រវត្តិរូបផ្ទាល់ខ្លួន ។ អំឡុងពេលនៃការឆ្លើយសំណួរនេះ ឌុច បានរៀបរាប់ពី ប្រវត្តិនៃការបង្រៀននិងការដែលគាត់ចូលក្នុងចលនាកុម្មុយនីស្ត ។ ឌុច បាននិយាយថា គាត់យល់ពីកុម្មុយនីស្តដំបូងដោយសារតែគាត់ស្តាប់អំពីការថ្លែងសុន្ទរកថារបស់ ម៉ៅ សេទុង ទាក់ទងទៅនឹងទ្វិភាក្ស

នៅប្រទេសចិនដែល ឌុច មានសមាជិកគ្រួសាររស់នៅទីនោះកាលពីជំនាន់នោះ ។ ក្រោយមក គាត់បានចូលបដិវត្តន៍ព្រោះគាត់មិនចង់អង្គុយមើលស្ងៀមទេក្រោយពីរដ្ឋប្រហារ លន់ នល់ រួច ។ គាត់ត្រូវបានណែនាំឲ្យចូលបក្សកុម្មុយនីស្តកម្ពុជាដោយ សុន សេន ដែលជាប្រធានទីមួយរបស់គាត់ ហើយ សុន សេន ជាមនុស្សដែលគាត់ធ្លាប់ស្គាល់ពីមុនមក ។ ក្នុងឆ្នាំ១៩៦៥គាត់បានទិញ«សៀវភៅចម្រើនជាច្រើនក្បាល» ដើម្បីសិក្សាពីលិទ្ធិសង្គមនិយម និងក្រោយមក គាត់បានចូលព្រៃក្នុងឆ្នាំ១៩៦៧ ។ គាត់ត្រូវបានដាក់គុកក្នុងឆ្នាំ១៩៦៨ដោយសារតែនិន្នាការរបស់គាត់ ហើយក្រោយមក គាត់បានធ្វើដំណើរចូលទៅ«តំបន់រំដោះ»ក្រោយពីចេញពីគុករួច ។

នៅពេលសួរអំពីមេដឹកនាំខ្មែរក្រហម ឌុច បាននិយាយថា គាត់មិនដែលឮឈ្មោះ ប៉ុល ពត ទេ អំឡុងពេលដំណាក់កាលដំបូងពេលដែលគាត់ចូលជាមួយខ្មែរក្រហម តែនៅពេលនោះគាត់ឮអំពី អៀង សារី ហើយ«មានមនោសញ្ចេតនាខ្លះ»ចំពោះ ខៀវ សំផន ។ អំឡុងពេលមុនរបបកម្ពុជាប្រជាធិបតេយ្យ ឌុច បានសិក្សាអំពី«មាក្ស៍»បក្ស និងឯកសារឃោសនាផ្សេងទៀត ។ គាត់រីករាយនិងអានសៀវភៅអំពីទ្រឹស្តីរបស់ ម៉ៅ សេទុង ។ គាត់បានអានខិត្តប័ណ្ណអំពីរដ្ឋប្រហារ លន់ នល់ ឮអំពីការធ្វើឃាតមកលើប្រធានាធិបតី ចន កេណ្ណឌី និងការធ្វើឃាតមេដឹកនាំវៀតណាម ព្រមទាំងហេតុការណ៍ផ្សេងទៀតដែលសម្រួចទស្សនៈរបស់គាត់នៅពេលនោះ ។ បុព្វហេតុនានាបង្កឲ្យមាន«ជាតិនិយម» ។ ឌុច បានរៀបរាប់ពីព្រឹត្តិការណ៍ដោយសង្ខេបខ្លះៗមុននឹងកើតរដ្ឋប្រហារ លន់ នល់ ក្នុងឆ្នាំ១៩៧០ និងការបះបោរនៅសំឡូត ព្រមទាំងការបង្កើតមូលដ្ឋានបផ្អែកខ្មែរក្រហមជាដើម ។

ដំបូង គាត់ត្រូវបានតែងតាំងធ្វើជាប្រធានមន្ទីរម-១៣ សម្រាប់«តំបន់ពិសេស»ដែលទើបតែបង្កើតថ្មីនៅក្នុងតំបន់រំដោះ ។ មន្ទីរនោះផ្លាស់ប្តូរទីតាំងជាច្រើនលើកច្រើនសារ ។ ឌុច បានផ្តល់សក្ខីកម្មថា គាត់«ក្នុងនាម»ជាសមាជិកបក្ស ត្រូវតែ«ទទួលយក»នូវការចាត់តាំងទាំងអស់ដោយបក្សកុម្មុយនីស្តកម្ពុជា ។ មន្ទីរម-១៣មានភារកិច្ចសួរចម្លើយ និង«សម្លាប់»ចំពោះអ្នកដែលត្រូវបានចោទថាជាខ្មាំង ។ គាត់ត្រូវបានបញ្ជាឲ្យសម្លាប់អ្នកទោសទាំងអស់ ហើយទុកតែអ្នកទោស៣០នាក់ប៉ុណ្ណោះ តែមានអ្នកទោសម្នាក់បានគាស់គុក ហើយរត់រួច ។ ក្រោយពីមានការគាស់គុក តាម៉ុក បានព្រមានគាត់ឲ្យមានប្រុងប្រយ័ត្ននៅពេលបញ្ជូនខ្មាំងចូលគុក ។ មកដល់ពេលនេះ អង្គជំនុំជម្រះប្រកាសសម្រាក ។

ក្រោយពីសម្រាក ព្រះរាជអាជ្ញាចាប់ផ្តើមសួរពីសកម្មភាពរបស់ ឌុច នៅ«តំបន់២៥» ។ ឌុច បានបញ្ជាក់ថា តំបន់នេះដើមឡើយត្រូវបានរំដោះដោយវៀតណាមទេ ដែលហៅតំបន់នេះថា «តំបន់៦២» ។ វៀតណាមគ្រប់គ្រងតំបន់នេះ ដែលជាតំបន់មានភោគផលហូរហៀរ ហើយវៀតណាមទទួលបានពន្ធអាករជាច្រើនដោយសារតែតំបន់នេះ ។ មកដល់ឆ្នាំ១៩៧០ តំបន់នេះត្រូវបានប្រគល់ជូនមក

កម្ពុជាវិញ ។ កាលពីដំបូង ឌុច មិនមានការផ្សារភ្ជាប់ទៅនឹងតំបន់២៥ទេ តែក្រោយមកគាត់ត្រូវបាន ហៅឲ្យទៅរៀនសូត្រពីឯកសារមួយចំនួនដែលគាត់ធ្លាប់សិក្សាពីមុនរួចមកហើយដូចជា "សង្គ្រាមប្រជាជន" និងយុទ្ធសាស្ត្រសង្គ្រាមឈ្លបជាដើម ។ ក្រោយពីរៀនសូត្រពីវគ្គនេះរួចមក គាត់ត្រូវបានផ្លាស់ទៅនៅភូមិភាគនិរតី និងតែងតាំងជាប្រធានមន្ទីរម-១៣ ។ ឌុច បានបញ្ជាក់ទៀតថា គាត់មិនដឹងទេថាហេតុអ្វីបានជាគាត់ត្រូវបានតែងតាំងឲ្យកាន់តំណែងនេះ តែគាត់បានបញ្ជាក់ថា តាម៉ុក បាន"វាយរំលំវណ្ណៈជិះជាន់"នៅភូមិភាគនិរតី ។ ឌុច និយាយថា តាម៉ុកប្រាប់គាត់ថា "បើសិនជាយើងធ្វើស្រែយើងហូបបាយ ។ បើយើងអានសៀវភៅយើងហូបក្រដាស" ។ តាម៉ុក បានបញ្ជាក់ទៀតថា "កសិករយើងប្រៀបដូចជាស្មៅអីចឹង គឺដុះនៅគ្រប់ទីកន្លែងទាំងអស់" ។ ក្រោយមក ឌុច បានបញ្ជាក់ថា ហ្វ្រង់ស័រ ប៊ីហ្សូ បានរៀបរាប់ពីបញ្ហានេះនៅក្នុងសៀវភៅរបស់គាត់ដែរ តែបានបកប្រែខុសជាភាសា ខ្មែរដូចជាពាក្យ"លះបង់"មកប្រើពាក្យ"ពលកម្ម"វិញ ។

មកដល់ចំណុចនេះ មេធាវី ម៉ៃខល ខារណាវ៉ាស របស់ជនជាប់ចោទ អៀង សារី និយាយគាត់ដោយអះអាងថា ការឆ្លើយដ៏វែងអន្លាយរបស់ ឌុច មិនចំសំណួរទេ ហើយការឆ្លើយបែបនេះរិតតែធ្វើឲ្យដំណើរការនេះអូសបន្លាយទៅមុខ ហើយធ្វើឲ្យមានការភ័ន្តច្រឡំ ។ មេធាវី ខារណាវ៉ាស បានស្នើទៅអង្គជំនុំជម្រះឲ្យណែនាំ ឌុច ឲ្យដាក់ដែនកំណត់ក្នុងការឆ្លើយសំណួររបស់គាត់ ។

អង្គជំនុំជម្រះយល់ស្របជាមួយមេធាវី ខារណាវ៉ាស ហើយបានណែនាំ ឌុច ឲ្យឆ្លើយឲ្យចំសំណួរ ហើយក្រោយមក អង្គជំនុំជម្រះបានឲ្យភាគីព្រះរាជអាជ្ញាបន្តសំណួរទៀត ។

សេង ប៊ុនឃាង បានសួរទៅ ឌុច ថាហេតុអ្វីបានជាគាត់ទទួលតំណែងជាប្រធានមន្ទីរម-១៣? ឌុច បានឆ្លើយតបទៅវិញថា គាត់បានពន្យល់អំពី "បុព្វបទ"នៃស្ថានភាពនៅភូមិភាគនិរតីថា "បញ្ញាវន្តត្រូវបានបង្ខំឲ្យធ្វើការ" ហើយកាលនោះគាត់ត្រូវបានបង្ខំឲ្យធ្វើជានគរបាល តែក្រោយមកគាត់ក្លាយជាប្រធានមន្ទីរម-១៣ ។

បន្ទាប់មក សេង ប៊ុនឃាង បានស្នើទៅ ឌុច ឲ្យរៀបរាប់អំពីការដែលចាត់ទុកនរណាម្នាក់ ជា "គិញ" ។ ឌុច បានឆ្លើយថា ជនជាប់ចោទជាគិញអាចជាអ្នកមាននិងអ្នកក្រ ហើយត្រូវបានបញ្ជូនទៅមន្ទីរស-២១ដើម្បីសម្លាប់ចោល ។ គាត់បានទុកអ្នកទោសមួយចំនួនដែរ តែអ្នកដែលដែលត្រូវបានបញ្ជូនទៅទីនោះត្រូវបានចាត់ទុកជាសត្រូវរួចទៅហើយ គឺត្រូវតែសម្លាប់ចោល ។

អ្នកទោសនៅមន្ទីរម-១៣ ត្រូវទទួលរងនូវទារុណកម្មមុននឹងសម្លាប់ ។ ទាក់ទងទៅនឹងគោលនយោបាយនៃការធ្វើទារុណកម្មនិងសម្លាប់ ឌុច បានបញ្ជាក់ថា វ៉ន វ៉េត បានប្រាប់ ឌុច ពីរបៀបសួរចម្លើយដោយប្រើថង់ផ្លាស់ស្ទិកដើម្បីគ្របមុខអ្នកទោស ។ វ៉ន វ៉េត បានប្រាប់ ឌុច ឲ្យសម្ងឹងមើល

បំពង់កររបស់អ្នកទោស បើសិនជាបំពង់ករនោះញ័រខ្លាំង នោះគឺជាគិញហើយ ដូច្នេះត្រូវតែកម្ទេចចោល ។ ឌុច បានបញ្ជាក់ថា អ្នកទោសប្រមាណជា២០០នាក់ត្រូវបានសម្លាប់នៅមន្ទីរម-១៣ ។ ឌុច បានបញ្ជាក់ថា មន្ទីរ១០៥ជាអ្នកមើលពីលើមន្ទីរម-១៣ ។ ឌុច បានឲ្យដឹងទៀតថា វ៉ន វ៉េត និង សុន សេន គឺជាអ្នកទទួលខុសត្រូវមន្ទីរពីរនេះដែលជាមន្ទីររបស់សមាជិកគណៈកម្មាធិការមជ្ឈិម ។ ក្រោយមក ឌុច បានបញ្ជាក់ទៀតថា គាត់បានទៅមន្ទីររបស់ វ៉ន វ៉េត និង សុន សេន និងមនុស្សពីរនាក់ទៀតដើម្បីទទួលការរៀនសូត្រដោយមានការណែនាំពី ប៉ុល ពត ។ ក្រោយពីរៀនសូត្រចប់ សមាជិកគណៈកម្មាធិការនេះបានត្រលប់ទៅវិញហើយទៅណែនាំកម្មាភិបាលថ្នាក់ក្រោមបន្ត អំពីមាគ៌ានយោបាយដែរ ហើយការបង្រៀននេះត្រូវចំណាយពេលពីរសប្តាហ៍ ។ ដូច្នេះ រៀងរាល់ឆ្នាំ កម្មាភិបាលថ្នាក់មូលដ្ឋានទទួលនូវវគ្គបណ្តុះបណ្តាលចំនួនពីរសប្តាហ៍អំពីគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ស្ថានភាពខ្លាំង និងហេតុការណ៍នៅសមរភូមិ ។ អំឡុងពេលនៃវគ្គសិក្សានេះ កម្មាភិបាលថ្នាក់ក្រោមក៏ទទួលបាននូវការរៀនសូត្រទាក់ទងទៅនឹងបញ្ហាសីលធម៌និងការដឹកនាំដែរ ។ ឌុច ក៏បានបន្តថា សមាជិកបក្សកុម្មុយនីស្តកម្ពុជាទទួលបាននូវសៀវភៅបក្សកុម្មុយនីស្តកម្ពុជារៀងរាល់ខែ ដែលកម្មាភិបាលទាំងអស់ត្រូវតែដឹងអំពីមាគ៌ារបស់បក្ស ។

នៅពេលដែលមន្ទីរម-១៣ ត្រូវបានបិទ ឌុច បានឲ្យដឹងថា មានអ្នកទោសខ្លះត្រូវបានដោះលែង ហើយអ្នកទោសខ្លះត្រូវបានបញ្ជូនទៅគុកផ្សេងទៀត អ្នកទោសខ្លះទៀតត្រូវបានកម្ទេចចោល ។ គាត់បានណែនាំអនុប្រធានរបស់គាត់នៅមន្ទីរម-១៣អំពីមាគ៌ារបស់បក្សព្រោះសមាជិកបក្សទាំងអស់ត្រូវតែបង្ហាត់បង្រៀនកូនចៅរបស់ខ្លួន ។ គាត់បានបង្រៀននៅមន្ទីរម-១៣អំពីរបៀបនៃការសួរចម្លើយ និងធ្វើទារុណកម្មអ្នកទោស ។ នៅពេលសួរថា តើគាត់រៀនពីរបៀបធ្វើទារុណកម្មនិងសួរចម្លើយពីណាមក? ឌុច បានរំឭកទៅព្រះរាជអាជ្ញាវិញថា គាត់ធ្លាប់ជាប់គុកនៅឆ្នាំ១៩៦៨ គាត់បានរៀនពីវិធីសាស្ត្រសួរចម្លើយ និងធ្វើទារុណកម្មនៅពេលដែលគាត់ត្រូវបានសួរចម្លើយ ក្រោយមក គាត់បានយកវិធីសាស្ត្រទាំងអស់នោះមកអនុវត្ត“ក្នុងការងារផ្ទាល់របស់គាត់” ។

ក្រោយមក ឌុច បានបញ្ជាក់ទៀតថា ពាក្យ “កម្ទេច” មិនទាន់ប្រើប្រាស់នៅឡើយទេ តែកាលនោះច្រើនប្រើពាក្យ “ដោះស្រាយ” ដែលមានន័យថា សម្លាប់ ។ តែ ឌុច ក៏បានបញ្ជាក់ថា ពាក្យទាំងពីរនេះហាក់បីដូចជាខុសគ្នា តែអត្ថន័យគឺ តែមួយគឺសម្លាប់ ។

ទាក់ទងទៅនឹងគំរូនៃមន្ទីរសន្តិសុខ ឌុច បានបញ្ជាក់ថា មន្ទីរសន្តិសុខរបស់ខ្មែរក្រហមគឺ “អនុវត្តតាមវិធីបុរាណ” ដែលសល់ពីសម័យឥស្សរៈ ហើយមន្ទីរទាំងអស់ត្រូវបានរៀបចំដូចសម័យនោះដែរ ។ ឌុច បានដឹងទៀតថា ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ មន្ទីរសន្តិសុខទាំង១៩៦មិនត្រូវបានអនុញ្ញាត

ឲ្យទាក់ទងគ្នាទេ។ នៅមន្ទីរ ស-២១ ឌុច បានបញ្ជាក់ថា បុគ្គលិកទាំងអស់ត្រូវបានណែនាំ ឲ្យវាយប្រកសៀ្បវពូលាសស៊ីក ធ្វើឲ្យថប់ដង្ហើម និងឆក់ខ្សែភ្លើងអ្នកទោសដែលជាវិធីក្នុងការធ្វើទារុណកម្ម។

## ចៅក្រមសុំទោស ឌុច ស្របពេលដែលព្រះរាជអាជ្ញាព្យាយាមផ្តល់ឲ្យ ឌុច នូវអ្វីដែលគាត់ធ្លាប់និយាយពីមុនមក

មកដល់ចំណុចនេះ អង្គជំនុំជម្រះត្រៀមនឹងសម្រាកសម្រាប់ថ្ងៃនេះ តែចៅក្រម និល ណុន បានណែនាំទៅមន្ត្រីរបស់តុលាការទាំងអស់ឲ្យដូរសម្លៀកបំពាក់របស់ "ជនជាប់ចោទ" សម្រាប់ថ្ងៃក្រោយ ដោយនិយាយនេះសំដៅទៅលើ ឌុច ដែលនៅក្នុងបន្ទប់សវនាការនៅពេលនេះក្នុងនាមជាសាក្សី។ ចៅក្រម និល ណុន បាននិយាយថា ឌុច មកទីនេះក្នុងនាមជាសាក្សី ហើយមិនគួរស្លៀកពាក់ឯកសណ្ឋានរបស់មន្ទីរឃុំឃាំងទេ។

មេធាវីរបស់ព្រះរាជអាជ្ញា វីល្លៀម ស្មីត បានក្រោកឡើងហើយបានថ្លែងអំណរគុណដល់ក្រុមការពារក្តីរបស់ អៀង សារី ដែលបានស្នើថា សក្ខីកម្មរបស់ ឌុច ហាក់មានលក្ខណៈវែងពេកនិងមិនត្រូវចំណុច។ វីល្លៀម ស្មីត ក៏បានជូនដំណឹងអង្គជំនុំជម្រះដែរថា ភាគីព្រះរាជអាជ្ញាបានត្រៀមសំណួររួចហើយដើម្បីសួរទៅ "ជនជាប់ចោទ" (ដោយសំដៅលើ ឌុច) ហើយពេលនេះព្រះរាជអាជ្ញាបានស្នើសុំការណែនាំដើម្បីផ្តល់ជូនឯកសារទៅ ឌុច។

មេធាវី ម៉ៃខល ផេសមិន បានជំទាស់ទៅនឹងសំណើរបស់ព្រះរាជអាជ្ញា តែបានស្នើថាសាក្សីគួរតែនាំចេញពីបន្ទប់សវនាការជាមុនសិនមុននឹងស្នើបែបនេះ។

ក្រោយពីអង្គជំនុំជម្រះសុំទោស ឌុច ហើយនាំគាត់ចេញពីបន្ទប់សវនាការ មេធាវី ផេសមិន បានឆ្លើយតបទៅនឹងសំណើរបស់ វីល្លៀម ស្មីត ឲ្យផ្តល់បញ្ជីឯកសារទៅ ឌុច។ មេធាវី ផេសមិន បានរំឭកទៅអង្គជំនុំជម្រះអំពីការជំទាស់ជាបឋមទៅនឹងការអនុវត្តន៍នៃការផ្តល់ជូនសាក្សីនូវអ្វីដែលគាត់បាននិយាយពីមុន ជាពិសេសទៅនឹងការប្រើប្រាស់ការអនុវត្តក្នុងករណីរបស់ ឌុច។

មេធាវី ផេសមិន បានអះអាងថា ការធ្វើបែបនេះបង្កឲ្យមានការភ័ន្តច្រឡំ។ ក្រោយមកមេធាវី ខារណាវ៉ាស បានឡើងបញ្ជាក់ពីគោលជំហររបស់ក្រុមការពារក្តីរបស់ អៀង សារី ដែលហាក់បីដូចជាមិនគាំទ្រទៅនឹងជំហររបស់ក្រុមការពារក្តីរបស់ នួន ជា។ មេធាវី ខារណាវ៉ាស បានបញ្ជាក់ថានៅតុលាការអន្តរជាតិ សាក្សីមានបទដ្ឋានក្នុងការទទួលនូវអ្វីដែលសាក្សីធ្លាប់និយាយពីមុនរួចហើយ តែគាត់មិនយល់ថាការអនុវត្តបែបនេះជាការល្អទេ។ បន្ទាប់មក ភាគីដើមបណ្តឹងរដ្ឋប្បវេណីផ្តល់ការគាំទ្រទៅនឹងសំណើរបស់ព្រះរាជអាជ្ញា។

វីល្មៀម ស្មីត បានសុំទោសទៅអង្គជំនុំជម្រះដែលបានលើកប្រធានបទច្បាប់នេះមកនិយាយនៅទីបញ្ចប់បែបនេះ គាត់បានបន្តដោយពន្យល់ថា មន្ត្រីផ្នែកច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងអង្គជំនុំជម្រះផ្ទាល់បានយល់ព្រមទៅនឹងការអនុវត្តបែបនេះពីមុនរួចហើយ ភាគីព្រះរាជអាជ្ញារំពឹងថានឹងជួយសន្សំពេលខ្លះក្នុងអំឡុងពេលនៃការធ្វើសក្ខីកម្មរបស់ ឌុច បើសិនជាគាត់ បានអានឯកសារទុកជាមុនរួចព្រោះព័ត៌មានច្រើនណាស់ដែលមាននៅក្នុងឯកសារនោះ ។ ភាគីព្រះរាជអាជ្ញាស្នើឲ្យ ឌុច ធ្វើសក្ខីកម្មចំនួនប្រាំថ្ងៃ ដែលធ្វើឲ្យ ឌុច ក្លាយជាសាក្សីសំខាន់មួយ ។

អង្គជំនុំជម្រះយល់ព្រមទៅនឹងសំណើរបស់ព្រះរាជអាជ្ញាដោយបញ្ជាក់ថា អង្គជំនុំជម្រះបានឯកភាពទៅនឹងវិធាននេះរួចហើយ ។ ចៅក្រម និល ណុន បានបង្គាប់ឲ្យប្រធានមន្ទីរឃុំឃាំងនាំ ឌុច មកកាន់បន្ទប់សវនាការទៀតនៅថ្ងៃស្អែក ។ អង្គជំនុំជម្រះប្រកាសសម្រាក ។

**- ចប់ -**